# ថ្មគ្រឹះនៃសេចក្តីពិត

# Cornerstones of Truth



កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

សិក្សាអំពីភាពជាអ្នកដឹកនាំក្នុងគ្រិស្តបរិស័ទ

# ថ្មគ្រឹះនៃសេចក្ដីពិត

## Cornerstones of Truth

## ការសិក្សាអំពីគោលលទ្ធិនៃព្រះគម្ពីរ

បោះពុម្ពផ្សាយ លើកទីមួយ

ដោយ លោក Floyd C. Woodworth, Jr .

ជាមួយលោក David D. Duncan

សៀវភៅសម្រាប់សិក្សាដោយខ្លួនឯង

បង្កើតឡើង ដោយសហប្រតិបត្តិការជាមួយបុគ្គលិក សាកលវិទ្យាល័យ គ្លូបល

GLOBAL UNIVERSITY

Address of the Global University office in your area:

Global University – Battambang CAM Office
Salaa Hope Battambang – AOG
Phom Romcheck 4, Khum Ratanak
Srok Battambang
Battambang, CAMBODIA

Developed in cooperation with Global University Staff

School for Evangelism and Discipleship
Global University
1211 South Glenstone
Springfield, MO 65804
USA

Translated from the Third Edition 1997 (English)
First edition 2025 (Khmer)
© 2025 Global University

All right reserved
Khmer: *Cornerstones of Truth* by Floyd C. Woodworth, Jr. With David D. Duncan

Unless otherwise indicated, Scripture quotations are from The Khmer Standard Version © 2005 United Bible Societies.
Used by permission. All rights reserved.

PN 01.25.01 KHM

www.globaluniversity.edu
www.globalreach.org (Free pdf download)

Khmer version by Battambang CAM Translation office
Project Editor: Kelly Robinette
Head Translator: សេម សិទ្ធី (Sem Sithee)
Translation Staff:
សិទ្ធី ធីម៉ូថេ (Sithee Thimothay)

Additional Proofreading: សេម សិទ្ធី (Sem Sithee)

តើមានអ្វីថ្មីក្នុងការបោះពុម្ពនេះ៖

- និស្សិតត្រូវដាក់ពាក្យ និង ចុះឈ្មោះជាផ្លូវការ ដើម្បីទទួលបានការទទួលស្គាល់
- និស្សិតអាចចុះឈ្មោះដោយផ្ញើអ៊ីមែល ទៅកាន់ globaluniversitycambodia@gmail.com

**កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ**

ភាពពេញវ័យរបស់គ្រិស្តបរិស័ទ Christian Maturity

ព្រះរាជ្យ ឫទ្ធានុភាព និង សិរីរុងរឿង Kingdom, Power, and Glory

**ថ្មគ្រឹះនៃសេចក្តីពិត** Cornerstones of Truth

ក្រុមជំនុំគ្រិស្តបរិស័ទ ទាក់ទងនឹងព័ន្ធកិច្ច The Christian Church in Ministry

អំណោយទានខាងវិញ្ញាណ Spiritual Gifts

ការដោះស្រាយបញ្ហាជីវិត Solving Life's Problems

ការអធិស្ឋាន និង ការថ្វាយបង្គំ Prayer and Worship

ជំរំ ព្រះវិហារ និង ព្រះរាជវាំង Tents, Temples and Palaces

ជីវិតនៅក្នុងព្រះគ្រិស្ត Alive in Christ

ការចាប់ផ្តើមក្រុមជំនុំថ្មី Starting New Churches

ការអធិប្បាយ និង ការបង្រៀន Preaching and Teaching

មនុស្ស កិច្ចការ និង គោលដៅ People, Tasks and Goals

គ្រិស្តបរិស័ទដែលចេះទទួលខុសត្រូវThe Responsible Christian

ការស្វែងយល់ព្រះគម្ពីរ Understanding the Bible

ទីប្រឹក្សា គ្រូបង្រៀន និង មគ្គុទេសក៍ Counselor, Teacher and Guide

ការជួយគ្រិស្តបរិស័ទឲ្យលូតលាស់ Helping Christians Grow

ការចែកចាយដំណឹងល្អ Sharing the Good New

ការរស់នៅដ៏ពេញបរិបូណ៌ Abundant Living

# កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

## The Christian Service Series

*ថ្មគ្រឹះនៃសេចក្ដីពិត (Cornerstones of Truth)* គឺជាមុខវិជ្ជាទីបីក្នុងចំណោមមុខវិជ្ជាទាំង១៨ ហើយដែល ស្ថិត នៅក្នុងវគ្គសិក្សាទីមួយ។ ក្នុងកម្មវិធីនៃភាពជាសាវ័កដ៏ជាក់ស្តែងមួយនេះ សម្រាប់អ្នកដឹកនាំថ្មីៗ។ កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ គឺជាការសិក្សាមួយដើម្បីជួយសិស្សឲ្យបានលូតលាស់ នៅក្នុងទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះគ្រិស្ត និង ទំនាក់ទំនងជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រមទាំងឲ្យបានយល់កាន់តែប្រសើរឡើង អំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់ពួកគេ។

សិស្សនឹងបានសិក្សា អំពីប្រធានបទមូលដ្ឋានគ្រឹះនៃគ្រិស្តបរិស័ទ ដោយមានការបែងចែកជាមូលបទប្រាំមួយយ៉ាង នៅក្នុងវគ្គនីមួយៗ។ វគ្គសិក្សាទាំងនេះ សរសេរតាមបែបសន្ទនា និង មានភាពងាយស្រួលក្នុងការអាន។ តារាងខាងក្រោមនេះ បង្ហាញពីការរៀបចំវគ្គសិក្សានីមួយៗ សម្រាប់កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ។

| មូលបទ Theme | វគ្គទី១ Unit One | វគ្គទី២ Unit Two | វគ្គទី៣ Unit Three |
|---|---|---|---|
| ជីវិតខាងវិញ្ញាណ Spiritual Life | ភាពពេញវ័យរបស់គ្រិស្តបរិស័ទ Christian Maturity | ការអធិស្ឋាន និង ការថ្វាយបង្គំ Prayer and Worship | គ្រិស្តបរិស័ទដែលចេះទទួលខុសត្រូវ The Responsible Christian |
| ព្រះគម្ពីរ The Bible | ព្រះរាជ្យ ឫទ្ធានុភាព និង សិរីរុងរឿង Kingdom, Power, and Glory | ជំរំ ព្រះវិហារ និង ព្រះរាជវាំង Tents, Temples and Palaces | ការស្វែងយល់ព្រះគម្ពីរ Understanding the Bible |
| ទេវសាស្ត្រ Theology | ថ្មគ្រឹះនៃសេចក្ដីពិត Cornerstones of Truth | ជីវិតរស់នៅក្នុងព្រះគ្រិស្ត Alive in Christ | ទីប្រឹក្សា គ្រូបង្រៀន និង មគ្គុទេសក៍ Counselor, Teacher and Guide |
| ក្រុមជំនុំ The Church | ក្រុមជំនុំគ្រិស្តបរិស័ទទាក់ទងនឹងព័ន្ធកិច្ច The The Christian Church in Ministry | ការចាប់ផ្តើមក្រុមជំនុំថ្មី Starting New Churches | ការជួយគ្រិស្តបរិស័ទឲ្យលូតលាស់ Helping Christians Grow |
| ការបម្រើ Service | អំណោយទានខាងវិញ្ញាណ Spiritual Gifts | ការអធិប្បាយ និង ការបង្រៀន Preaching and Teaching | ការចែកចាយដំណឹងល្អ Sharing the Good News |
| ក្រមសីលធម៌របស់គ្រិស្តបរិស័ទ Christian Ethics | ការដោះស្រាយបញ្ហាជីវិត Solving Life's Problems | មនុស្ស កិច្ចការ និង គោលដៅ People, Tasks and Goals | ការរស់នៅដ៏ពេញបរិបូណ៌ Abundant Living |

# តារាងមាតិកា

កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ច របស់គ្រិស្តបរិស័ទ ........ ៦
សេចក្តីណែនាំ ........ ៧

## ជំពូកទី១: ព្រះជាម្ចាស់ដ៏ជាមហាក្សត្រ

១. ព្រះជាម្ចាស់៖ និស្ស័យ និង លក្ខណសម្បត្តិធម្មជាតិរបស់ទ្រង់ ........ ១៦
២. ព្រះជាម្ចាស់៖ លក្ខណសម្បត្តិខាងឯសីលធម៌ និង កិច្ចការរបស់ទ្រង់ ........ ៤៨
៣. ព្រះគ្រិស្ត៖ ការបង្ហាញឲ្យឃើញ អំពីព្រះជាម្ចាស់ដែលគេមិនអាចឃើញ ........ ៧៧
៤. ព្រះវិញ្ញាណដ៏វិសុទ្ធ៖ អ្នកគ្រប់គ្រងដែលប្រកបដោយប្រាជ្ញាញាណ ........ ១០៦

## ជំពូកទី២: ប្រធានបទអំពីព្រះជាម្ចាស់

៥. ទេវតា៖ កងទ័ពនៃភាពងងឹត និង កងទ័ពនៃពន្លឺ ........ ១៣៥
៦. មនុស្សជាតិ ៖ ប្រធានបទនៃព្រះអាទិករ ........ ១៦១
៧. អំពើបាប និង សេចក្តីសង្គ្រោះ៖ បញ្ហា និង ដំណោះស្រាយ ........ ១៨៧

## ជំពូកទី៣: ប្រព័ន្ធរបស់ព្រះជាម្ចាស់

៨. បទគម្ពីរ៖ ការបើកបង្ហាញជាសំណេរ របស់ព្រះជាម្ចាស់ ........ ២១៣
៩. ក្រុមជំនុំ៖ សហគមន៍នៃប្រជារាស្ត្រ របស់ព្រះជាម្ចាស់ ........ ២៣៩
១០. អនាគត៖ ការបើកបង្ហាញ រង្វាន់ និង ការសម្រាក ........ ២៦៥

អក្ខរានុក្រម ........ ២៩៨
ចម្លើយសម្រាប់ការប្រឡងផ្ទាល់ខ្លួន ........ ៣១១
ការប្រឡងតាមជំពូក ........ ៣១៧
អវសានកថា ........ ៣៣២
សំណួរសម្រាប់និស្សិត ........ ៣៣៤

# កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

ជំពូក ១
មុខវិជ្ជា ៣

សៀវភៅសិក្សាផ្ទាល់ខ្លួននេះ គឺជាសៀវភៅមួយក្បាលក្នុងចំណោមសៀវភៅចំនួន១៨ក្បាល( មុខវិជ្ជា) ដែលជាមុខវិជ្ជាបណ្តុះបណ្តាល ក្នុងការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ នៃសាកលវិទ្យាល័យ គ្លូបល។ សញ្ញាសម្គាល់នៅខាងឆ្វេងដៃនេះ សម្រាប់បង្ហាញអំពីលំដាប់លំដោយនៃការសិក្សា មុខវិជ្ជានេះ ដែលត្រូវបែងចែកជា៣វគ្គដែលមាន ៦ មុខវិជ្ជានៅក្នុងវគ្គនីមួយៗ។ *ថ្មគ្រឹះនៃសេចក្តីពិត* (Cornerstones of Truth) ជាមុខវិជ្ជាទី៣ ក្នុងជំពូកទី១ ។

ជំពូកទាំងអស់ ត្រូវបានរៀបចំ ដើម្បីនាំអ្នក ឲ្យសិក្សាមុខវិជ្ជានេះ ជាលក្ខណៈប្រព័ន្ធសម្រាប់កម្មវិធីសិក្សាទាំងអស់នេះ ។ ប៉ុន្តែ អ្នកក៏អាចសិក្សា តែមុខវិជ្ជានេះមួយ ឬក៏អាចសិក្សា មុខវិជ្ជាផ្សេងៗទៀតបាននៅក្នុងកម្មវិធីសិក្សានេះ តាមរបៀបណាក៏បាន។

សម្ភារសិក្សានៅក្នុងកម្មវិធី ការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទនេះ ត្រូវបានបង្កើតឡើង ទៅតាមរបៀបមួយ ដែលឲ្យអ្នកបម្រើព័ន្ធកិច្ចគ្រិស្តបរិស័ទ គ្រប់ជាតិសាសន៍ និង គ្រប់វប្បធម៌ អាចរៀនដោយខ្លួនឯងបាន។ កម្មវិធីនេះនឹង ផ្តល់ជូននិស្សិត នូវចំណេះដឹង និង ជំនាញខាងព្រះគម្ពីរ សម្រាប់ការបម្រើយ៉ាងជាក់ស្តែងរបស់គ្រិស្តបរិស័ទ។

## កំណត់សម្គាល់

សូមអានការណែនាំដំបូង នៃមុខវិជ្ជានេះដោយប្រុងប្រយ័ត្នបំផុត។ ដោយធ្វើតាម ការណែនាំនេះ អ្នកនឹងអាចសម្រេចគោលដៅមុខវិជ្ជារបស់អ្នក ហើយអ្នកនឹងគ្មានការលំបាកក្នុងការវាយតម្លៃ ក្នុងជំពូករបស់អ្នកឡើយ។

# សេចក្ដីណែនាំ

តើអ្វីជាការសិក្សាអំពីគោលលទ្ធិ?

តើអ្វីទៅ ដែលបិតានៃឥណ្ឌាសម័យថ្មីលោកមហាត្មះ គន្ធី ចាត់ទុកថាជាជំងឺនៃសតវត្សទីម្ភៃនេះ? ហេតុអ្វីបានជាលោកបៃនីតូ  ហ្វារ៉េស ជ្រើសបំបែកក្រុមជំនុំចេញពីរដ្ឋនៅក្នុងប្រទេស មិចស៊ីកូ?

ដើម្បីស្វែងយល់អំពីអ្វីដែលអ្នកទាំងនេះ និង មនុស្សល្បីល្បាញដទៃទៀត បានបង្រៀនអំពីប្រធានបទណាមួយ តាមធម្មតាយើងអាចនឹងត្រូវអានស្នាដៃសំណេររបស់ពួកគាត់ទាំងអស់។ នៅក្នុងករណីរបស់លោកមហាត្មះ គន្ធី យើងអាចនឹងត្រូវអានសៀវភៅដល់ទៅ៨០ក្បាល! សាកគិតទៅមើលថា តើវាមានភាពងាយស្រួលកម្រិតណាសម្រាប់យើង ប្រសិនបើយើងអាចរកបានសៀវភៅមួយក្បាល ដែលបែងចែកអ្វីដែលគាត់បង្រៀនទៅតាមប្រធានបទនោះ។

យើងបានជួបបញ្ហាដូចគ្នានេះ នៅក្នុងការព្យាយាមសិក្សាប្រធានបទជាច្រើនដែលមានរៀបរាប់នៅក្នុងព្រះគម្ពីរ។ ដូចដែលអ្នកប្រហែលបានដឹងហើយថា សេចក្ដីបង្រៀននៅបទគម្ពីរ មិនត្រូវបានបង្ហាញដោយយោងទៅតាមប្រធានបទឡើយ។ ឧទាហរណ៍ កណ្ឌគម្ពីរលោកុប្បត្តិ មិនផ្ដល់នូវការបកស្រាយពេញលេញអំពី ភាពពេញលេញនៃព្រះត្រៃឯក ហើយក៏គ្មានសៀវភៅមួយក្បាលណាទៀតដែរ។

ដូច្នេះ របៀបមួយដ៏សំខាន់បំផុត ដើម្បីសិក្សាព្រះគម្ពីរ គឺត្រូវមើលទៅលើព្រះគម្ពីរទាំងមូល ដើម្បីស្វែងរកសេចក្ដីបង្រៀនដែលទាក់ទងនឹងប្រធានបទណាមួយ។ ការនេះ ជួយយើងឲ្យបានឃើញពីផ្នត់គំនិតទាំងមូលយ៉ាងរហ័ស ក៏ដូចជារៀបចំព័ត៌មានតាមរបៀបមួយដែលសមហេតុសមផល។ វាគឺជារបៀបជាក់ស្ដែងមួយ ដើម្បីរៀបចំការគិតរបស់យើង និង ដាក់ជីវិតរបស់យើងឲ្យនៅលើខ្សែបន្ទាត់នៃគោលការណ៍របស់ព្រះគម្ពីរ។

ឈ្មោះបច្ចេកទេសមួយសម្រាប់ការសិក្សាព្រះគម្ពីរបែបនេះ គឺ*ទេវវិទ្យាបែបប្រព័ន្ធ* ។ នៅក្នុងមុខវិជ្ជានេះ យើងនឹងដើរតាមគម្រោងបែបនេះ នៅពេលដែលយើងសិក្សាស្រាវជ្រាវ បទគម្ពីរដើម្បីឲ្យបានឃើញពីអ្វីដែលបទគម្ពីរទាំងនោះបង្រៀនអំពីសកលលោក អ្នកគ្រប់គ្រងសកលលោក ប្រធានបទ និង វចនាសម្ព័ន្ធដែលព្រះជាម្ចាស់បានជ្រើសរើសដើម្បីបង្កើតសកលលោកនេះឡើង ។ យើងក៏នឹងស្វែងរកឲ្យឃើញនូវអ្វីដែលព្រះគម្ពីររៀបរាប់អំពីថ្ងៃអនាគតផងដែរ។

ការពិនិត្យពិច័យជាប្រព័ន្ធមួយ ទៅលើអ្វីដែលព្រះគម្ពីរបានចែងអំពីបញ្ហាសំខាន់ៗ នឹងជួយយើងឲ្យបានដឹងពីអ្វីដែលយើងអាចរំពឹងបានពីព្រះជាម្ចាស់ និង អ្វីដែលទ្រង់រំពឹងពីយើង។ ជាលទ្ធផល យើងនឹងបានលូតលាស់នៅខាងវិញ្ញាណ។

# ការរៀបរាប់អំពីមុខវិជ្ជា

*ថ្មគ្រឹះនៃសេចក្តីពិត ។ ការសិក្សាអំពីគោលលទ្ធិនៃព្រះគម្ពីរ* គឺជាការសិក្សាតាមបែបប្រព័ន្ធជាលើកដំបូង ទៅលើមូលដ្ឋានគ្រឹះនៃគោលលទ្ធិនៅក្នុងព្រះគម្ពីរ។ ប្រធានបទចម្បងៗ រួមមាននិស្ស័យរបស់ព្រះជាម្ចាស់ កិច្ចការរបស់ព្រះជាម្ចាស់ សកម្មភាព និង ភាពមានកម្រិតរបស់ពួកទេវតា ការបង្កើតលោក ការធ្លាក់ចុះរបស់មនុស្សជាតិ ផែនការនៃការប្រោសលោះរបស់ព្រះជាម្ចាស់ ប្រភពដើមនៃបទគម្ពីរ ក្រុមជំនុំ និង ផែនការចុងក្រោយរបស់ព្រះជាម្ចាស់សម្រាប់មនុស្សជាតិ។ មុខវិជ្ជានេះ គឺជាការសិក្សាមូលដ្ឋានជាក់ស្តែងអំពីសេចក្តីបង្រៀននៅក្នុងព្រះជាម្ចាស់ និង ការប្រើប្រាស់សេចក្តីបង្រៀននោះនៅក្នុងជីវិតរបស់អ្នកជឿ។ ប្រធានបទដ៏ល្អៗនៃព្រះគម្ពីរ ត្រូវបានសិក្សា និង គាំទ្រដោយបទគម្ពីរយោងជាច្រើន។

# វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបានបញ្ចប់មុខវិជ្ជានេះ អ្នកអាចនឹង៖

១. រៀបរាប់អំពីលក្ខណសម្បត្តិជាព្រះ និង ជាបុគ្គលរបស់ព្រះដែលជាផ្នែករបស់ ភាពពេញលេញនៃព្រះត្រៃឯក។

២. រៀបរាប់ពីការបង្កើតមនុស្សជាតិ ការធ្លាក់ចុះរបស់មនុស្សជាតិ និង ដំណោះស្រាយដែលព្រះជាម្ចាស់ប្រទានមកដើម្បីស្រោចស្រង់ទំនាក់ទំនងរបស់មនុស្សជាតិជាមួយនឹងទ្រង់ឡើងវិញ។

៣. ប្រាប់អ្វីដែលយើងអាចដឹងអំពី ទេវតាល្អ និង ទេវតាអាក្រក់និង សកម្មភាពរបស់ពួកគេ។

៤. បកស្រាយគោលបំណង និង សកម្មភាពរបស់ក្រុមជំនុំ និង ផែនការរបស់ព្រះជាម្ចាស់សម្រាប់អនាគតដ៏អស់កល្បរបស់ក្រុមជំនុំនោះ។

៥. ប្តេជ្ញាចិត្ត ដើម្បីឲ្យគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិតរបស់អ្នក ទទួលបានការដឹកនាំ ដោយខ្នាតគំរូនៃជំនឿ និង ឥរិយាបថ ដែលផ្អែកទៅលើសេចក្តីពិតតាមព្រះគម្ពីរ។

# សៀវភៅមេរៀន

អ្នកនឹងប្រើប្រាស់សៀវភៅ *ថ្មគ្រឹះនៃសេចក្តីពិត* និពន្ធដោយលោក Floyd C. Woodworth, Jr, និង លោក David D. Duncan ទុកជាសៀវភៅមេរៀន និង ជាសៀវភៅមគ្គុទេសក៍ក្នុងការសិក្សា មុខវិជ្ជានេះផង។ ក្រៅពីនោះ អ្នកត្រូវការ តែព្រះគម្ពីរតែប៉ុណ្ណោះ។

# មុនពេលដែលអ្នកចាប់ផ្តើម

## របៀបរៀនមុខវិជ្ជានេះ

មុខវិជ្ជានេះត្រូវបានសរសេរឡើង ដើម្បីឲ្យអ្នកអាចយកទៅសិក្សាដោយខ្លួនឯងបាន។ យ៉ាងណាក៏ដោយអ្នកអាចរៀនមុខវិជ្ជានេះតាមការរៀបចំក្រុមផ្សេងៗ។ ប្រសិនបើអ្នករៀនដោយខ្លួនឯង ការរៀនរបស់អ្នក អាចបានចប់គ្រប់ជ្រុងជ្រោយ ដោយធ្វើតាមការណែនាំ នៅក្នុងសេចក្តីណែនាំនេះ។ ប្រសិនបើអ្នករៀនជាក្រុម សូមធ្វើតាមការណែនាំបន្ថែមផ្សេងដែលគ្រូរបស់អ្នកដាក់ឲ្យ ដោយយកចិត្តទុកដាក់។

## វិធីប្រើប្រាស់សៀវភៅនេះ

ពេលវេលាដែលអ្នកត្រូវការ សម្រាប់រៀនមេរៀននីមួយៗ អាស្រ័យទៅតាមផ្នែកខុសៗគ្នា ទៅលើចំណេះដឹងរបស់អ្នកចំពោះមុខវិជ្ជា និង ភាពស្ទាត់ជំនាញរបស់អ្នកក្នុងការសិក្សារៀនសូត្រ មុនពេលចាប់ផ្តើមមុខវិជ្ជានោះ។ ពេលវេលាដែលអ្នកត្រូវចំណាយ ក៏អាស្រ័យទៅលើ ថាតើអ្នកអាចធ្វើតាមការណែនាំបានខ្ជាប់ខ្ជួនប៉ុនណា ហើយតើអ្នកបានបង្កើនភាពស្ទាត់ជំនាញ ដែលចាំបាច់ក្នុងការសិក្សាដោយខ្លួនឯងនេះ បានល្អប៉ុនណាដែរ។ ការដាក់គម្រោងកាលវិភាគសិក្សារបស់អ្នក ជាប្រយោជន៍ឲ្យអ្នកអាចចំណាយពេលវេលាគ្រប់គ្រាន់ដើម្បីសម្រេចបានគោលដៅដែលអ្នកនិពន្ធបានដាក់ឲ្យ ក៏ដូចជាគោលដៅផ្ទាល់ខ្លួនរបស់អ្នកផងដែរ។

មេរៀននីមួយៗ រួមបញ្ចូលទាំងសេចក្តីណែនាំ គម្រោង និងវត្ថុបំណងដើម្បីនាំផ្លូវការសិក្សារបស់អ្នក មានទាំងសកម្មភាពក្នុងការរៀន ពាក្យសំខាន់ លំហាត់អនុវត្តន៍ក្នុងមេរៀន និងលំហាត់សាកល្បងផ្ទាល់ខ្លួននៅចុងមេរៀននីមួយៗ។ ចម្លើយនៃលំហាត់អនុវត្តន៍ មាននៅចុងបញ្ចប់មេរៀននីមួយៗ ហើយចម្លើយនៃលំហាត់សាកល្បងផ្ទាល់ខ្លួន មាននៅខាងចុងបញ្ចប់នៃសៀវភៅ ដូច្នេះអ្នកអាចរំឭកដំណើរការនៃការរៀនសូត្ររបស់អ្នកបាន។

## គំនិតយោបល់សម្រាប់ការសិក្សា

១. ញែកពេលវេលាឲ្យបានស្ងប់ស្ងាត់ និង ទៀងទាត់ សម្រាប់ការសិក្សារបស់អ្នក។ វាមានភាពងាយស្រួលក្នុងការផ្តោតអារម្មណ៍ជាជាង ប្រសិនបើការសិក្សាជាផ្នែកមួយនៃទម្លាប់របស់អ្នក។

២. អធិស្ឋានមុនពេលដែលអ្នកចាប់ផ្តើមការសិក្សារៀនសូត្ររបស់អ្នក។ ដោយមានព្រះគម្ពីរមួយ រួមទាំងព្រះវិញ្ញាណដ៏វិសុទ្ធ និង មុខវិជ្ជានេះ អ្នកនឹងបាននៅក្នុងថ្នាក់រៀននៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ទូលសូម ព្រះជាម្ចាស់ដើម្បីឲ្យទ្រង់ជួយអ្នក ស្វែងយល់មេរៀននេះ ហើយយកវានៅដាក់ក្នុងជីវិតរបស់អ្នក។

៣. អានសេចក្តីណែនាំ គម្រោង និងគោលដៅ។ វានឹងផ្តល់ជូនអ្នកនូវសេចក្តីសង្ខេបទូទៅរបស់មេរៀន ជួយអ្នកឲ្យផ្តោតការយកចិត្តទុកដាក់របស់អ្នកទៅលើចំណុចសំខាន់ក្នុងពេលដែលអ្នកកំពុងសិក្សា ហើយវានឹងប្រាប់អ្នកពីអ្វីដែលអ្នកត្រូវរៀន។

៤. អានមេរៀនដោយប្រុងប្រយ័ត្ន។ បើកមើលខគម្ពីរយោង និងធ្វើការកត់ត្រាក្នុងសៀវភៅកត់ត្ររបស់អ្នក ដែលអាចមានប្រយោជន៍។ ខគម្ពីរ ជួយបញ្ជាក់បន្ថែមពីលើចំណុចសំខាន់របស់មេរៀន។

៥. ឆ្លើយលំហាត់អនុវត្តន៍ នៅក្នុងចន្លោះដែលបានដាក់ឲ្យ។ ចម្លើយដែលវែងអាចសរសេរនៅក្នុងសៀវភៅកត់ត្រារបស់អ្នកក៏បាន។ ពេលអ្នកសរសេរ ចម្លើយរបស់អ្នកសូម កត់ត្រាលេខរៀង និងចំណងជើងមេរៀនផងដែរ។ **សូមកុំមើលចម្លើយ ភ្លាមៗឡើយ។** ការឆ្លើយចម្លើយដោយខ្លួនឯង នឹងជួយឲ្យអ្នកចងចាំមេរៀនដែលអ្នកបានរៀន។ បន្ទាប់ពីឆ្លើយលំហាត់អនុវត្តន៍រួចហើយ ផ្ទៀងផ្ទាត់ចម្លើយរបស់អ្នកជាមួយចម្លើយដែលបានផ្តល់ជូននៅខាងចុងនៃមេរៀន បន្ទាប់មកពិនិត្យមើលសាឡើងវិញនូវចម្លើយដែលអ្នកឆ្លើយខុស។ ចម្លើយដែលយើងឲ្យ គឺមិននៅតាមលំដាប់លំដោយលេខរៀងទេ ដូច្នេះអ្នកនឹងមិនអាចមើលឃើញចម្លើយនៃសំណួរបន្ទាប់ដោយចៃដន្យឡើយ។ លំហាត់អនុវត្តន៍ទាំងនេះពិតជាសំខាន់ខ្លាំងណាស់។ ពួកវានឹងជួយឲ្យអ្នកបានចងចាំគំនិតសំខាន់របស់មេរៀន ហើយប្រើប្រាស់គោលការណ៍ដែលអ្នកបានរៀនហើយ។

៦. នៅចុងបញ្ចប់នៃមេរៀននីមួយៗ ចូរធ្វើលំហាត់សាកល្បងផ្ទាល់ខ្លួន បន្ទាប់មកពិនិត្យមើលចម្លើយរបស់អ្នកដោយប្រើ តារាងចម្លើយនៅផ្នែកខាងក្រោយនៃសៀវភៅ។

៧. នៅចុងបញ្ចប់នៃជំពូកនីមួយៗ សូមឆ្លើយសំណួរនៃការប្រឡងតាមជំពូកនោះ។

៨. ចំណាយពេលវេលារបស់អ្នក និង រៀននៅកន្លែងស្ងប់ស្ងាត់។

## របៀបឆ្លើយសំណួរសិក្សា

មានលំហាត់សិក្សា និង សំណួរសាកល្បងខ្លួនឯងជាច្រើនប្រភេទនៅក្នុងសៀវភៅនេះ។ នៅខាងក្រោមនេះជាមួយឧទាហរណ៍នៃប្រភេទសំណួរនីមួយៗ និងរបៀបឆ្លើយសំណួរ។ ការពន្យល់បញ្ជាក់បន្ថែមនឹងផ្តល់ជូនសម្រាប់ប្រភេទសំណួរផ្សេងៗទៀត។

## សំណួរពហុជម្រើស

សំណួរពហុជម្រើសតម្រូវឲ្យអ្នកជ្រើសរើសចម្លើយមួយក្នុងចំណោមចម្លើយដែលបានឲ្យ។

ឧទាហរណ៍

១. កណ្ឌគម្ពីរសរុបមានចំនួន

ក. ១០០កណ្ឌ

(ខ.) ៦៦កណ្ឌ

គ. ២៧កណ្ឌ

ចម្លើយត្រឹមត្រូវគឺ ខ. ៦៦កណ្ឌ។ អ្នកអាចគូសរង្វង់ជុំវិញ អក្សរ ខ. ដូចដែលបានបង្ហាញនៅខាងលើ។

( សម្រាប់សំណួរពហុជម្រើសខ្លះ មានចម្លើយត្រឹមត្រូវលើសពីមួយ។ ក្នុងករណីនេះ ចូរគូសរង្វង់ជុំវិញអក្សរ នៃចម្លើយត្រឹមត្រូវនីមួយៗ។)

# ចម្លើយត្រូវ/ខុស

ចំណុចឬ សំណួរត្រូវ/ខុស តម្រូវឲ្យអ្នកជ្រើសរើសចម្លើយពីរ ឬ បី ដែលត្រឹមត្រូវ។

## ឧទាហរណ៍

១. តើឃ្លាប្រយោគខាងក្រោមនេះ ប្រយោគណាខ្លះ ដែលត្រឹមត្រូវ?

(ក.) ព្រះគម្ពីរជាព្រះរាជសារសម្រាប់ ពួកអ្នកជឿនៅសព្វថ្ងៃនេះ។

ខ. ព្រះគម្ពីរសរុបទាំងអស់ មាន១២០កណ្ឌ។

(គ.) ព្រះវិញ្ញាណដ៏វិសុទ្ធបានបំភ្លឺឲ្យអ្នកនិពន្ធតាក់តែងព្រះគម្ពីរ

ប្រយោគ ក. និង គ. គឺជាចម្លើយត្រឹមត្រូវ។ អ្នកត្រូវគូសរង្វង់ពីលើអក្សរ ទាំងពីរនេះ ដូចបានបង្ហាញក្នុងឧទាហរណ៍ស្រាប់។

# សំណួរផ្គូផ្គង

សំណួរផ្គូផ្គង តម្រូវឲ្យអ្នកផ្គូផ្គងអ្វីដែលត្រូវគ្នា។

## ឧទាហរណ៍

៣. ចូរសរសេរលេខនៃឈ្មោះអ្នកដឹកនាំ នៅពីមុខប្រយោគដែលនិយាយពីសកម្មភាពពួកគេបានធ្វើ។

..1...ក) បានទទួលក្រឹត្យវិន័យ នៅលើភ្នំស៊ីណៃ — ១) ម៉ូសេ

..2...ខ) បានដឹកនាំជនជាតិអ៊ីស្រាអែល ឆ្លងកាត់ទន្លេយ័រដាន់ — ២) យ៉ូស្វេ

..2...គ) បានដើរក្បួនជុំវិញ ក្រុងយេរីខូ

..1...ឃ) បានរស់នៅក្នុងវាំងរបស់ស្តេចផារ៉ោន

ឃ្លា ក) និង ឃ) និយាយអំពី លោកម៉ូសេ ហើយ ឃ្លា ខ) និង គ) និយាយអំពីលោកយ៉ូស្វេ។ អ្នកត្រូវតែ សរសេរលេខ ១ នៅត្រង់ ក) និង ឃ) ហើយសរសេរលេខ ២ នៅត្រង់ ខ) និង គ) ដូចបានបង្ហាញក្នុងឧទាហរណ៍ស្រាប់។

# ការប្រឡងតាមជំពូក

នៅចុងបញ្ចប់នៃ មុខវិជ្ជានេះ អ្នកនឹងឃើញការប្រឡងតាមជំពូក និង តារាងចម្លើយ។ សូមធ្វើតាមការណែនាំដែលបានដាក់ជូនដោយប្រុងប្រយ័ត្ន។ ឆ្លើយសំណួរទាំងអស់ រួចផ្ញើតារាងចម្លើយរបស់អ្នកទៅឲ្យគ្រូរបស់អ្នកធ្វើការកែតម្រូវ។ បន្ទាប់មកអ្នកអាចធ្វើការ រំឭកសាឡើងវិញនូវមុខវិជ្ជានេះ ហើយ និង សំណួរដែលទាក់ទងជាមួយព្រះគម្ពីរដែលគិតថាពិបាកសម្រាប់អ្នក ។ ការរំឭកសាឡើងវិញ នូវវត្ថុបំណង សំណួរនិងចម្លើយលំហាត់អនុវត្តន៍ និងការប្រឡងផ្ទាល់ខ្លួននិងចម្លើយរបស់វានៅក្រោយសៀវភៅនេះ វាជួយអ្នកឲ្យត្រៀមខ្លួនសម្រាប់ការប្រឡងតាមជំពូក។ សម្រាប់និស្សិតដែលរៀនតាមរយៈការិយាល័យជាតិ ឬ ក្រុមសិក្សាតាមតំបន់ អាចទាក់ទងគ្រូ ឬ អ្នកដឹកនាំរបស់ពួកគេ ដើម្បីទទួលបានព័ត៌មានអំពីការប្រឡងតាមជំពូក។ ប្រសិនបើ អ្នកមិនបានរៀនជាផ្លូវការតាមរយៈសាកលវិទ្យាល័យគ្លូបល ឬក្រុមសិក្សាទេ អ្នកនៅតែអាចទទួលបានផលប្រយោជន៍ពីការប្រឡងតាមជំពូកនេះដែរ។

# អំពីអ្នកនិពន្ធ

លោក Floyd C. Woodworth, Jr.,ត្រូវបានជ្រើសតាំងជាព្រឹទ្ធបូជាចារ្យតាំងពីឆ្នាំ១៩៥១ មក។ ថ្មីៗនេះ លោកគឺជាអ្នកត្រួតពិនិត្យឯកសារអប់រំសម្រាប់ Christian Training Network ហើយលោកជាសាស្ត្រាចារ្យនៅក្នុងthe Latin American Advanced School of Theology ។ លោក Woodworth ធ្លាប់បានបម្រើការនៅប្រទេស គុយបា រហូតដល់ឆ្នាំ១៩៦៣។ នៅឆ្នាំ ១៩៦៤ លោកបានក្លាយជានាយកនៃសាលាព្រះគម្ពីរCentral នៅប្រទេសColombia នៃអាមេរិកខាងត្បូង។ នៅឆ្នាំ ១៩៧៣ លោកត្រូវបានគេចាត់បញ្ជូនទៅប្រទេស ម៉ិចស៊ីកូ ដែលនៅទីនោះលោកបានចូលរួម ក្នុងការបង្កើតឯកសារអប់រំគ្រិស្តបរិស័ទ តាមរយៈកម្មវិធីអប់រំគ្រិស្តបរិស័ទជាន់ខ្ពស់ ដែលមកដល់សព្វថ្ងៃត្រូវបានគេស្គាល់ថា Christian Training Network។

លោក Woodworth បានសិក្សានៅក្នុងមហាវិទ្យាល័យព្រះគម្ពីរ Central នៅទីក្រុង Springfield, Missouri និង នៅក្នុងមហាវិទ្យាល័យ Bethany Peniel នៅទីក្រុងBethany, នៅរដ្ឋOklahoma ជាកន្លែងដែលលោកទទួលបានសញ្ញាប័ត្រ BA។ លោកបានទទួលសញ្ញាប័ត្រអនុបណ្ឌិតខាងសិល្បៈអក្សរសាស្ត្រ Spanish-American ពីសាកលវិទ្យាល័យ Southern California នៅរដ្ឋLos Angeles។ លោកធ្វើការនិពន្ធ ចេញពីបទពិសោធន៍ដ៏ច្រើនរបស់គាត់ ដូចជាគ្រូបង្រៀននៅក្នុងសាលាព្រះគម្ពីរ ជាគ្រូគង្វាល និង ជាអ្នកផ្សាយដំណឹងល្អម្នាក់។ ការបង្រៀនរបស់លោកផ្អែកទៅលើមូលដ្ឋានគ្រឹះឆ្លងវប្បធម៌ផ្សេងៗ បានផ្តល់លក្ខណៈ និង ចំណេះដឹងយ៉ាងពិសេសទៅដល់ការនិពន្ធរបស់លោក។

លោក David Duncan បានធ្វើជាបេសកជនតាំងពីឆ្នាំ ១៩៦៨។ លោកបានបម្រើការជាគ្រូបង្រៀន និង ជានាយក នៅវិទ្យាស្ថានព្រះគម្ពីរ Calvary, នៅទីក្រុងMajuro, Marshall Islands, អស់រយៈពេលប្រាំបីឆ្នាំ ហើយលោកបានបង្រៀននៅមហាវិទ្យាល័យព្រះគម្ពីរContinental នៅទីក្រុងBrussels, រដ្ឋBelgium និង បានបម្រើជាអ្នកគ្រប់គ្រង ការរៀបចំសំណេរសំណៅដើមនៅ សាកលវិទ្យាល័យ ICI ចាប់តាំងពីឆ្នាំ ១៩៨០ ទៅដល់ឆ្នាំ១៩៨៣។ លោកមានទាំងសញ្ញាប័ត្រ BA និង MA ពីសាកលវិទ្យាល័យ Fullerton នៃរដ្ឋ California ។ លោកក៏បានបញ្ចប់វគ្គសិក្សាដែលជាការកំណត់នូវកម្រិតសិក្សា Doctor of ministry នៅGraduate school of theology នៃរដ្ឋCalifornia។